ការិយាល័យទទួលបន្ទុកកិច្ចការស្តីពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

## ប្រទេសកម្ពុជា

## របាយការណ៍ ឆ្នាំ ២០១០ ស្តីពីសេរីភាពសាសនាអន្តរជាតិ

រដ្ឋធម្មនុញ្ញ គោលនយោបាយ និងច្បាប់ដទៃទៀតការពារសេរីភាពសាសនាហើយ ជាទូទៅនិងជាក់ស្តែង រដ្ឋាភិបាលការពារសេរីភាពសាសនា។ ពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ។

ជាទូទៅ រដ្ឋាភិបាលគោរពសេរីភាពសាសនា តាមច្បាប់ និងក្នុងស្ថានភាពជាក់ស្តែង។ ស្ថានភាពនៃការគោរពសេរីភាពសាសនាមិនមានការប្រែប្រួលទេ នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។

មានករណីតិចតួចត្រូវបានរាយការណ៍មកស្តីពីការបំពានឬការរើសអើងពីសង្គម ដោយសារការចូលសាសនា ជំនឿ ឬការប្រតិបត្តិសាសនា។

រដ្ឋាភិបាលអាមេរិកពិភាក្សាពីសេរីភាពសាសនាជាមួយរដ្ឋាភិបាលកម្ពុជា ជាផ្នែកមួយនៃនយោបាយរួមរបស់ខ្លួនដើម្បីលើកកំពស់សិទ្ធិមនុស្ស។

### ផ្នែក ១៖ ប្រជាសាស្ត្រទាក់ទងនឹងសាសនា

ប្រទេសកម្ពុជាមានផ្ទៃដីចំនួន ៦៧ ០០០ ម៉ៃល៍ការេ ហើយមានប្រជាជនចំនួន ១៣,៤ លាននាក់។ ប្រជាជនចំនួន ៩៣% កាន់ពុទ្ធសាសនាហិនយាន ដែលមានកាន់ជាទូទៅនិងយ៉ាងរឹងមាំ ក្នុងខេត្ត ក្រុងទាំងអស់ ដោយមានវត្តចំនួនប្រមាណ ៤ ៣៩២ នៅទូទាំងប្រទេស។ ជនជាតិខ្មែរភាគច្រើនលើសលុបជាពុទ្ធសាសនិក ។ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាងពុទ្ធសាសនា ប្រពៃណីវប្បធម៌ខ្មែរ និងជីវិតរស់នៅប្រចាំថ្ងៃ។ ការប្រតិបត្តិតាមព្រះពុទ្ធសាសនាត្រូវបានចាត់ទុកជាទូទៅថា ចាំបាច់នៅក្នុងអត្តសញ្ញាណវប្បធម៌ និងអត្តសញ្ញាណជនជាតិនៅប្រទេសកម្ពុជា។ សាលាពុទ្ធិកមហាយានមានអ្នកប្រតិបត្តិតាមចំនួន ៣៥០០០ នាក់ ហើយមានវត្តចំនួន ១០៥ នៅទូទាំងប្រទេស។

មានអ្នកកាន់សាសនាឥស្លាមប្រមាណពី ៣,៥% ទៅ ៥% នៃប្រជាជនសរុប ដែលភាគច្រើនលើសលុបគឺចាម។ ពួកគេច្រើនរស់នៅតាមទីប្រជុំជននិងភូមិនេសាទតាមជនបទ  តាមមាត់ទន្លេសាបនិងទន្លេមេគង្គ និងនៅក្នុងខេត្តកំពត ។ នៅកម្ពុជា សាសនាឥស្លាមមាន

បួនសាខា គឺសាខាស៊ីអាដែលទទួលឥទ្ធិពលពីម៉ាឡេ ហើយដែលប្រតិបត្តិដោយអ្នកកាន់សាសនាឥស្លាមចំនួន ៨៨% ។ សាខា Salafi ដែលទទួលឥទ្ធិពលពីប្រទេសគុយវេតនិងអារ៉ាប៊ីសាអ៊ូឌីត (ពេលខ្លះ គេហៅថា "Wahhabi") ដែលមានអ្នកជឿប្រមាណ ៦% នៃអ្នកកាន់សាសនាឥស្លាម តែចំនួននេះចេះតែមានការកើនឡើង ។ សាខាដើម ដែលមាន ឈ្មោះថា Iman-San ដែលប្រតិបត្តិដោយអ្នកជឿចំនួន ៣% និងសាខា Kadiani ដែលមានអ្នកជឿ ៣% ដែរ ។ មានវិហារឥស្លាមចំនួនពី ២៨០ និងមានវិហារឥស្លាម Surav តូចៗ៣៧៤ ដែលជាកន្លែងប្រជុំមានអ្នកចូលរួមរហូតដល់ ៤០ នាក់ ហើយមិនមានកន្លែងសំរាប់គ្រូប្រដៅសាសនាឈរធ្វើធម្មទេសនានៅថ្ងៃសុក្រទេ ។ **សាខាងទាំង ៤ មាន**Surav ហើយខុសពីវិហារឥស្លាមធំតែត្រង់សំណង់ស្ថាបត្យកម្មតែប៉ុណ្ណោះ ដោយវាច្រើនតូច ហើយសង់នៅតាមតំបន់ជនបទ។

អ្នកកាន់សាសនាគ្រីះដែលមានចំនួនតិចតួច ត្រូវជាប្រមាណ ២% នៃប្រជាជនសរុប ។ មាននិកាយឬអង្គការសាសនាគ្រីះប្រមាណ ១០០ ដែលធ្វើសកម្មភាពដោយសេរីនៅទូទាំងប្រទេស ។ មានវិហារគ្រីះចំនួន ១ ២៩២ (១ ២២៤ ជាវិហារប្រូតេស្តង់ និង ៦៨ ជាវិហារកាតូលិក) នៅកម្ពុជា ។ ក្រៅពីនេះ មានបន្ទប់សំរាប់បន់ស្រន់ ឬថ្វាយបង្គំចំនួន ៨៨៣ និងសាលាសាសនាចំនួន ២៤៨ ។ តែក្នុងចំណោមនេះ មានតែវិហារចំនួនប្រមាណ ១ ០០០ ប៉ុណ្ណោះដែលបានចុះបញ្ជីការជាផ្លូវការ ។ អង្គការសាសនាដទៃទៀតដែលមានអ្នកជឿមិនច្រើន មានសាសនា Cao Dai របស់វៀតណាម ដែលមានអ្នកកាន់ចំនួន ៣ ០០០ នាក់ និងអ្នកកាន់សាសនា Baha'i Faith ចំនួន ១០ ០០០ នាក់។

**ផ្នែកទី ២. ស្ថានភាពនៃសេរីភាពសាសនា**

*ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ*

សូមមើលសេចក្ដីបន្ថែម គ ក្នុងរបាយការណ៍ស្ដីពីការអនុវត្តន៍សិទ្ធិមនុស្ស បើចង់ដឹងពីការទទួលរបស់រដ្ឋាភិបាលចំពោះបទដ្ឋានគតិយុត្តិអន្តរជាតិ http://www.state.gov/g/drl/rls/hrrpt/2010/appendices/index.htm ។

រដ្ឋធម្មនុញ្ញ គោលនយោបាយ និងច្បាប់ដទៃទៀតការពារសេរីភាពសាសនាហើយ ជាទូទៅនិងជាក់ស្ដែង រដ្ឋាភិបាលការពារសេរីភាពសាសនា។ រដ្ឋធម្មនុញ្ញហាមប្រាមការរើសអើងដោយសារសាសនា ហើយរដ្ឋាភិបាលមិនអត់ឱនចំពោះការរំលោភសេរីភាពសាសនាឡើយ ទោះប្រព្រឹត្តឡើងដោយមនុស្សក្នុងជួររដ្ឋាភិបាល ឬក្នុងវិស័យឯកជនក៏ដោយ។ ពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ ហើយរដ្ឋាភិបាលជំរុញអោយមានថ្ងៃបុណ្យតាមព្រះពុទ្ធសាសនា ផ្ដល់ការបណ្ដុះបណ្ដាល និងការអប់រំដល់ព្រះសង្ឃ និងអ្នកដទៃទៀតនៅតាមវត្ត ហើយជួយមួយផ្នែកតូចដល់វិទ្យាស្ថានមួយ ដែលធ្វើការស្រាវជ្រាវ និងបោះពុម្ពឯកសារវប្បធម៌ខ្មែរ និងប្រពៃណីតាមព្រះពុទ្ធសាសនា។

ច្បាប់តំរូវអោយក្រុមអ្នកកាន់សាសនាទាំងអស់ រួមទាំងក្រុមពុទ្ធសាសនិកផង អោយដាក់ពាក្យសុំទៅក្រសួងធម្មការនិងសាសនា បើគេចង់កសាងកន្លែងគោរពបូជា ឬធ្វើសកម្មភាពផ្សេងៗផ្នែកសាសនា ។ នៅក្នុងពាក្យសុំរបស់គេ គេត្រូវបញ្ជាក់អោយច្បាស់ពីបំណង និងសកម្មភាពផ្នែកសាសនារបស់គេ ដែលត្រូវតែគោរពតាមបញ្ញត្តិ ហាមប្រាមក្រុមសាសនានានាមិនអោយប្រមាថក្រុមសាសនាដទៃទៀត បង្កើតអោយមានជំលោះ ឬ ប៉ះពាល់ដល់សន្តិសុខជាតិ ។ មិនមានការដាក់ពិន័យចំពោះការមិនចុះបញ្ជីការទេ ហើយជាក់ស្តែងមានក្រុមខ្លះមិនបានចុះបញ្ជីទេ ។

រដ្ឋាភិបាលធ្វើការចែកដាច់ពីគ្នាខាងផ្លូវច្បាប់ រវាងព្រះវិហារ និងបន្ទប់ធ្វើការបន់ស្រន់ ឬថ្វាយបង្គំ។ ការបង្កើតព្រះវិហារតំរូវអោយស្ថាបនិកមានអាគារ និងដីដែលព្រះវិហារនោះស្ថិតនៅលើ។ កន្លែងនោះត្រូវដាក់មនុស្សបានយ៉ាងតិច ២០០ នាក់ ហើយពាក្យសុំការអនុញ្ញាតត្រូវមានការគាំទ្ររបស់បរិស័ទយ៉ាងតិច ១០០ នាក់។ ផ្ទុយទៅវិញ បន្ទប់សំរាប់ធ្វើការថ្វាយបង្គំអាចស្ថិតនៅទីតាំងឬអាគារជួល ហើយគ្មានការកំណត់ចំនួនមនុស្សដែលអាចស្ថិតនៅក្នុងនោះទេ។ ពាក្យសុំការអនុញ្ញាតតំរូវអោយមានអ្នកគាំទ្រតែ ២០ នាក់ប៉ុណ្ណោះ។

បទបញ្ញត្តិពីការគ្រប់គ្រងសាសនាពីខាងក្រៅតំរូវអោយមានការចុះបញ្ជីកន្លែងគោរពបូជានិងសាលាសាសនា ជាបន្ថែមលើការយល់ព្រមរបស់រដ្ឋាភិបាល មុនពេលធ្វើការសាងសង់កន្លែងគោរពបូជាថ្មីៗ ។ កន្លែងគោរពបូជាត្រូវស្ថិតនៅឆ្ងាយពីគ្នាយ៉ាងតិច ២ គម ហើយមិនអាចប្រើប្រាស់ដើម្បីបំរើបំណងផ្នែកនយោបាយ ទទួលឧក្រិដ្ឋជនអោយស្នាក់នៅ ឬជនគេចខ្លួនពីច្បាប់ឡើយ ។ ការកំណត់ព្រំដែនពីគ្នានេះត្រូវបានអនុវត្តទាក់ទងតែនឹងការកសាងកន្លែងគោរពបូជាថ្មីៗតែប៉ុណ្ណោះ ហើយមិនទាក់ទងនឹងការិយាល័យរបស់អង្គការសាសនាទេ ។ មិនមានសេចក្តីរាយការណ៍ដែលនិយាយថាបទបញ្ញានេះត្រូវបានប្រើដើម្បីរារាំងវិហារសាសនាមិនអោយកសាងទីតាំងថ្មីទេ។បទបញ្ញានេះក៏បានតំរូវផងដែរថាមិនអោយក្រុមសាសនាធ្វើការរិះគន់ដោយចំហលើក្រុមដទៃទៀតទេ តែបទបញ្ញាតិនេះកំរត្រូវបានយកមកអនុវត្តណាស់។

រដ្ឋាភិបាលអនុញ្ញាតអោយមានការបង្រៀនពីពុទ្ធសាសនានៅតាមសាលារដ្ឋនានា ។ ការបង្រៀនពីសាសនាដទៃទៀត នៅតាមសាលារដ្ឋត្រូវបានហាមឃាត់ តែការបង្រៀនពីសាសនាដែលមិនមែនជាសាសនាព្រះពុទ្ធនៅតាមសាលាឯកជនអាចធ្វើទៅបាន។

រដ្ឋាភិបាលកំណត់យកថ្ងៃបុណ្យធំៗតាមសាសនា ជាថ្ងៃឈប់សំរាកទូទាំងប្រទេសគឺ ថ្ងៃចូលឆ្នាំខ្មែរ ថ្ងៃភ្ជុំបិណ្ឌ វិសាកបូជា និងមាឃបូជា

*ការរិតត្បិតលើសេរីភាពសាសនា*

ជាទូទៅ រដ្ឋាភិបាលគោរពសេរីភាពសាសនា ទាំងតាមផ្លូវច្បាប់ ទាំងក្នុងភាពជាក់ស្តែង។ មិនមានការផ្លាស់ប្តូរក្នុងស្ថានភាពនៃការគោរពសេរីភាពសាសនា ដោយរដ្ឋាភិបាលទេ  នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។

មិនមានលឺពីការចាប់ឃុំមនុស្សដោយសារសាសនាទេ នៅក្នុងប្រទេស។

## ផ្នែកទី ៣. សកម្មភាពរបស់សង្គមដែលប៉ះពាល់ដល់ការទទួលបានសេរីភាពសាសនា

ពុំមានសេចក្តីរាយការណ៍ពីការរំលោភឬការរើសអើងពីសង្គមច្រើនទេ ទាក់ទងនឹងការចូល ការប្រតិបត្តិ ឬជំនឿសាសនា ។

មិនដូចនៅឆ្នាំ ២០០៩ ទេ អ្នកកាន់សាសនាគ្រឹះនិងអ្នកកាន់សាសនាឥស្លាមគ្មានការប៉ះទង្គិចគ្នាក្នុងមូលដ្ឋានទេ ។ ប្រជាជនចាមរស់នៅដោយចុះសំរុងល្អនៅក្នុងសង្គម មានទទួលមុខនាទីធំៗក្នុងផ្នែកជំនួញនិងក្នុងរដ្ឋាភិបាល តែចំនួនទាំងនេះនៅទាប បើប្រៀបធៀបនឹងក្រុមសាសនាដទៃទៀត ហើយការអង្កេតទៅលើប្រជាជនចាមបានបង្ហាញអោយឃើញថា ពួកគេនៅតែយល់ឃើញពីឧបសគ្គផ្នែកវប្បធម៌ និងផ្នែកស្ថាប័នសំរាប់សមាហរណកម្មពេញលេញក្នុងសង្គម។

## ផ្នែកទី ៤. គោលនយោបាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក

រដ្ឋាភិបាលសហរដ្ឋអាមេរិកពិភាក្សាបញ្ហាសេរីភាពសាសនាជាមួយរដ្ឋាភិបាលកម្ពុជា ជាផ្នែកមួយនៃគោលនយោបាយរួមរបស់ខ្លួនក្នុងការលើកកំពស់សិទ្ធិមនុស្ស ។ តំណាងរបស់ស្ថានទូតអាមេរិកមានការទាក់ទងជាមួយក្រុមសាសនាគ្រឹះ សាសនាឥស្លាម និង ពុទ្ធសាសនា ព្រមទាំងជាមួយមេដឹកនាំអង្គការសាសនាជាច្រើនផងដែរ។

ស្ថានទូតអាមេរិកបានបន្តសកម្មភាពជាមួយអ្នកកាន់សាសនាឥស្លាម ។ ការងារនេះផ្តល់ជាប្រភពព័ត៌មានបន្ថែមស្តីពីស្ថានភាពនៃការចេះអត់ឱន និងការចេះរស់នៅដោយសុខស្រួលរបស់ប្រជាជនកាន់សាសនាឥស្លាម ជាមួយក្រុមមនុស្សដទៃៗទៀត។  ស្ថានទូតមានកម្មវិធីអាហារូបករណ៍សំរាប់ការសិក្សាភាសាអង់គ្លេសរយៈពេល ២ ឆ្នាំ សំរាប់សិស្សកាន់សាសនាឥស្លាម ហើយបានបន្តផ្តល់ថវិកាគាំទ្រដល់ស្ថានីយវិទ្យុសំលេងភាសាចាម ដែលជា កម្មវិធីវិទ្យុផ្សាយសំលេងតែមួយគត់នៅកម្ពុជាដែលផ្សាយជាភាសាចាម ។ កម្មវិធីនេះផ្តល់ជាវេទិកាសំរាប់ពិភាក្សាពីបញ្ហាសាសនា និងបញ្ហាដទៃទៀត។ ស្ថានទូតបានបន្តធ្វើការជាមួយវត្តមួយចំនួនតាមផ្លូវសាសនា ដើម្បីជួយអ្នកផ្ទុកមេរោគអេដស៍ និងអ្នករងការប៉ះពាល់ដោយជំងឺអេដស៍